**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលលោកជំទាវ Manika Jain ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកជំទាវ Manika Jain ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលានៅទីស្តីការក្រសួង ក្នុងឱកាសដែលលោកជំទាវបញ្ចប់បេសកកម្មការទូតនៅកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះលោក**ជំទាវឯកអគ្គរដ្ឋទូត** ដែលបានបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យនៅកម្ពុជា និងបានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការរួមចំណែករបស់**លោកជំទាវ**ក្នុងការពង្រឹងនិងលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានចូលរួមរំលែកទុក្ខជាមួយរដ្ឋាភិបាល និងប្រជាជនឥណ្ឌាដល់ជនរងគ្រោះដោយសារទឹកជំនន់ ការរអិលបាក់ដី និងជំងឺរាតត្បាតសកលកូវីដ-១៩ ផងដែរ។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់រដ្ឋាភិបាល និងប្រជាជនឥណ្ឌាចំពោះការផ្តល់ជំនួយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមដល់ប្រទេសកម្ពុជា រួមមាន ជំនួយឥតសំណង កម្ចីសម្បទាន អាហារូបករណ៍ជាដើម។ ជាងនេះទៅទៀត ឥណ្ឌាក៏បានផ្តល់ប្រព័ន្ធអនុគ្រោះពន្ធដល់កម្ពុជា ដោយធ្វើឲ្យទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរកើនឡើងជាលំដាប់ ជាក់ស្តែងទំហំពាណិជ្ជកម្មមានការកើនឡើងពីជាង២០៥ លានដុល្លារក្នុងឆ្នាំ២០១៨ ដល់ជាង២៥៥ លានដុល្លារក្នុងឆ្នាំ២០១៩។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ចង់ឃើញកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ឥណ្ឌាសម្រេចបានក្នុងពេលឆាប់ខាងមុខនេះដើម្បីជំរុញវិស័យពាណិជ្ជកម្មនៃប្រទេសទាំងពីរឲ្យកាន់តែប្រសើរឡើងថែមទៀត។ បន្ថែមលើនេះ ដោយឃើញវិស័យទេសចរណ៍នៃប្រទេសទាំងពីរមានការរីកចម្រើនខ្លាំង **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជំរុញឲ្យមានការហោះហើរត្រង់កម្ពុជា-ឥណ្ឌា ដើម្បីធ្វើឲ្យវិស័យនេះកាន់តែរីកចម្រើនថែមទៀត។

ជាការឆ្លើយតប **លោកជំទាវ ឯកអគ្គរដ្ឋទូត** បានសំដែងក្តីរីករាយ និងថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការផ្តល់កិច្ចសហការយ៉ាងល្អ ជាពិសេសតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលរួមចំណែកធ្វើឲ្យការបំពេញបេសកកម្មការទូតរបស់លោកជំទាវនៅកម្ពុជា ទទួលបានជោគជ័យ។ **លោកជំទាវ**បន្ថែមថានៅក្នុងអាណត្តិរបស់លោកជំទាវ ទំនាក់ទំនងនៃប្រទេសទាំងពីរមាន

ការរីកចម្រើនខ្លាំងគួរឲ្យកត់សម្គាល់។ នៅក្នុងក្របខណ្ឌទ្វេភាគី មានការផ្លាស់ប្ដូរទស្សនកិច្ចថ្នាក់ដឹកនាំ និងមានកិច្ចសហប្រតិបត្តិការជាច្រើនរួមមានវិស័យយោធា អប់រំ វប្បធម៌ និងបោសសំអាតមីន ជាពិសេស អំឡុងពេលទស្សនកិច្ចផ្លូវការរបស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី**ក្នុងប្រទេសឥណ្ឌាកាលពីឆ្នាំ២០១៨ មានកិច្ចព្រមព្រៀងចំនួនបួនត្រូវបានចុះហត្ថលេខាៈ ព័ត៌មានវិទ្យា ទេសចរណ៍ អប់រំ វប្បធម៌ និងការអនុវត្តច្បាប់ ។ ជាងនេះទៅទៀត ភាគីទាំងពីរបានឯកភាពគ្នាលើកកម្រិតកិច្ចប្រជុំគណៈកម្មការចម្រុះដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ពីថ្នាក់អនុរដ្ឋមន្ត្រី មកថ្នាក់រដ្ឋមន្ត្រីការបរទេសវិញ ចាប់ពីឆ្នាំ២០២០នេះ។

**លោកជំទាវ ឯកអគ្គរដ្ឋទូត** មានការវាយតម្លៃខ្ពស់លើវិស័យសុខាភិបាលកម្ពុជា ដែលបាននិងកំពុងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដោយជោគជ័យ ហើយដែលធ្វើឲ្យប្រជាពលរដ្ឋ មន្ត្រីស្ថានទូតឥណ្ឌា និងរូបលោកជំទាវផ្ទាល់ទទួលបាននូវសុវត្ថិភាពក្នុងពេលធ្វើដំណើរ បំពេញការងារ និងស្នាក់នៅក្នុងប្រទេសកម្ពុជា។

កម្ពុជា និងឥណ្ឌាមានកិច្ចសហប្រតិបត្តិការយ៉ាងល្អទាំងក្នុងយន្តការតំបន់ និងអន្តរជាតិ។ ចំពោះយន្តការតំបន់ កម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយឥណ្ឌាក្នុងក្របខ័ណ្ឌមេគង្គ-គង្គា និងអាស៊ាន-ឥណ្ឌា។ **លោកជំទាវ** ក៏បានរំលេចអំពីការទន្ទឹងរង់ចាំនូវការសម្រេចឱ្យបានឆាប់នូវផ្លូវហាយវ៉េត្រីភាគីរវាងឥណ្ឌា-ថៃ-មីយ៉ានម៉ា ក៏ដូចជាលទ្ធភាពក្នុងការពង្រីកផ្លូវហាយវ៉េនេះទៅភ្ជាប់ជាមួយនឹងកម្ពុជាឡាវ និងវៀតណាម។ នៅក្នុងវេទិកាអន្តរជាតិ ប្រទេសទាំងពីរតែងតែផ្ដល់កិច្ចគាំទ្រគ្នាទៅវិញទៅមកផងដែរ។

ភាគីទាំងពីរ ក៏បានផ្លាស់ប្ដូរទស្សនៈគ្នាផងដែរ លើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួន ដែលជាកង្វល់ និងការចាប់អារម្មណ៍រួម ៕